ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ៤៤៧/៥៣១ ប្រក.កសក.សហវ

ប្រកាសរួម

ស្តីពី

តម្លៃទីផ្សារជាមូលដ្ឋាននៃផល អនុផលព្រៃឈើ ដើម្បីពិន័យអន្តរការណ៍

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

និង

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអនុក្រឹត្យទាំងឡាយដែលតម្លើង បំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអនុក្រឹត្យទាំងឡាយដែលតម្លើង បំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញការចាំបាច់

សម្រេច

ប្រការ ១ : ត្រូវបានកំណត់ឱ្យប្រើប្រាស់នូវតម្លៃទីផ្សារជាមូលដ្ឋាននៃឈើជ្រុង ឈើអារ តាមបណ្តារាជធានី ខេត្ត ដើម្បីពិន័យ អន្តរការណ៍ នៅទូទាំងប្រទេសដូចក្នុងតារាងខាងក្រោម :

(គិតជារៀល/ម៣)

ល.រ	ខេត្ត	ឈើប្រណិត					ឈើលេខ១	ឈើលេខ២	ឈើលេខ៣ និងក្រៅលំដាប់
		ក្រញូង	ក្រាក់ក្រញូង	បេង	នាងនួន	ធ្នង់			
១	សៀមរាប	៥ ៤៦០ ០០០	២ ១០០ ០០០	២ ៥២០ ០០០	២ ៥២០ ០០០	២ ១០០ ០០០	១ ១៧៦ ០០០	១ ០៥០ ០០០	៦៣០ ០០០
២	បន្ទាយមានជ័យ	៥ ៤៦០ ០០០	២ ១០០ ០០០	២ ៥២០ ០០០	២ ៥២០ ០០០	២ ១០០ ០០០	១ ២៦០ ០០០	១ ១៣៤ ០០០	៦៣០ ០០០
៣	ឧត្តរមានជ័យ	៥ ០៤០ ០០០	១ ៦៨០ ០០០	២ ១០០ ០០០	២ ១០០ ០០០	១ ៦៨០ ០០០	១ ០៥០ ០០០	៩២៤ ០០០	៦៣០ ០០០
៤	ព្រះវិហារ	៥ ០៤០ ០០០	១ ៦៨០ ០០០	២ ១០០ ០០០	២ ១០០ ០០០	១ ៦៨០ ០០០	១ ០៥០ ០០០	៩២៤ ០០០	៦៣០ ០០០
៥	កំពង់ធំ	៥ ៤៦០ ០០០	២ ១០០ ០០០	២ ៥២០ ០០០	២ ៥២០ ០០០	២ ១០០ ០០០	១ ១៧៦ ០០០	១ ០៥០ ០០០	៦៣០ ០០០
៦	ស្វាយរៀង	៦ ៣០០ ០០០	២ ៩៤០ ០០០	៣ ៣៦០ ០០០	៣ ៣៦០ ០០០	២ ៩៤០ ០០០	១ ៣០២ ០០០	១ ១៧៦ ០០០	៨៤០ ០០០
៧	ព្រៃវែង	៦ ៣០០ ០០០	២ ៩៤០ ០០០	៣ ៣៦០ ០០០	៣ ៣៦០ ០០០	២ ៩៤០ ០០០	១ ២១៨ ០០០	១ ១៧៦ ០០០	៨៤០ ០០០
៨	កំពង់ចាម	៦ ៣០០ ០០០	២ ៩៤០ ០០០	៣ ៧៨០ ០០០	៣ ៧៨០ ០០០	២ ៩៤០ ០០០	១ ១៣៤ ០០០	១ ០៥០ ០០០	៧១៤ ០០០
៩	ក្រចេះ	៦ ៣០០ ០០០	២ ៩៤០ ០០០	២ ៩៤០ ០០០	២ ៩៤០ ០០០	២ ១០០ ០០០	១ ០៥០ ០០០	៩២៤ ០០០	៦៣០ ០០០
១០	ស្ទឹងត្រែង	៥ ៤៦០ ០០០	២ ១០០ ០០០	២ ៥២០ ០០០	២ ៥២០ ០០០	១ ៦៨០ ០០០	១ ០៥០ ០០០	៩២៤ ០០០	៦៣០ ០០០
១១	រតនគិរី	៦ ៣០០ ០០០	២ ៩៤០ ០០០	២ ៥២០ ០០០	២ ៥២០ ០០០	២ ១០០ ០០០	១ ០៥០ ០០០	៩២៤ ០០០	៦៣០ ០០០
១២	មណ្ឌលគិរី	៥ ៨៨០ ០០០	២ ៥២០ ០០០	២ ១០០ ០០០	២ ១០០ ០០០	១ ៦៨០ ០០០	១ ០៥០ ០០០	៩២៤ ០០០	៦៣០ ០០០
១៣	កណ្តាល	៦ ៣០០ ០០០	២ ៩៤០ ០០០	៤ ២០០ ០០០	៤ ២០០ ០០០	៣ ៧៨០ ០០០	១ ៥១២ ០០០	១ ៣៨៦ ០០០	១ ០៥០ ០០០
១៤	ភ្នំពេញ	៦ ៣០០ ០០០	២ ៩៤០ ០០០	៤ ២០០ ០០០	៤ ២០០ ០០០	៣ ៧៨០ ០០០	១ ៥១២ ០០០	១ ៣៨៦ ០០០	១ ០៥០ ០០០
១៥	កំពង់ស្ពឺ	៥ ៤៦០ ០០០	២ ១០០ ០០០	២ ៩៤០ ០០០	២ ៩៤០ ០០០	២ ៥២០ ០០០	១ ១៧៦ ០០០	១ ០៥០ ០០០	៦៣០ ០០០
១៦	កំពង់ឆ្នាំង	៥ ៤៦០ ០០០	២ ១០០ ០០០	៣ ៣៦០ ០០០	៣ ៣៦០ ០០០	២ ៩៤០ ០០០	១ ២៦០ ០០០	១ ១៣៤ ០០០	៨៤០ ០០០
១៧	ពោធិសាត់	៥ ០៤០ ០០០	១ ៦៨០ ០០០	២ ៩៤០ ០០០	២ ៩៤០ ០០០	២ ៥២០ ០០០	១ ០៥០ ០០០	៩២៤ ០០០	៦៣០ ០០០
១៨	បាត់ដំបង	៥ ៤៦០ ០០០	២ ១០០ ០០០	៣ ៣៦០ ០០០	៣ ៣៦០ ០០០	២ ៩៤០ ០០០	១ ២៦០ ០០០	១ ១៧៦ ០០០	៨៤០ ០០០
១៩	ប៉ៃលិន	៥ ៤៦០ ០០០	២ ១០០ ០០០	២ ៥២០ ០០០	២ ៥២០ ០០០	២ ១០០ ០០០	១ ០៥០ ០០០	៩២៤ ០០០	៨៤០ ០០០
២០	កំពត	៦ ៣០០ ០០០	២ ៩៤០ ០០០	២ ៩៤០ ០០០	២ ៩៤០ ០០០	២ ៥២០ ០០០	១ ៤៧០ ០០០	១ ៣៤៤ ០០០	១ ០៥០ ០០០
២១	តាកែវ	៦ ៣០០ ០០០	២ ៩៤០ ០០០	៣ ៣៦០ ០០០	៣ ៣៦០ ០០០	២ ៩៤០ ០០០	១ ៥៩៦ ០០០	១ ៤៧០ ០០០	១ ០៥០ ០០០

២២	កែប	៦ ៣០០ ០០០	២ ៩៤០ ០០០	២ ៩៤០ ០០០	២ ៩៤០ ០០០	២ ៥២០ ០០០	១ ៥៩៦ ០០០	១ ៤៧០ ០០០	៩៦៦ ០០០
២៣	ព្រះសីហនុ	៦ ៣០០ ០០០	២ ៩៤០ ០០០	៣ ៣៦០ ០០០	៣ ៣៦០ ០០០	២ ៩៤០ ០០០	១ ៤៧០ ០០០	១ ៣៤៤ ០០០	៩៦៦ ០០០
២៤	កោះកុង	៥ ០៤០ ០០០	២ ៥២០ ០០០	២ ៩៤០ ០០០	២ ៩៤០ ០០០	២ ៥២០ ០០០	១ ០៥០ ០០០	៩២៤ ០០០	៦៣០ ០០០

ប្រការ ២ : រាល់តម្លៃទីផ្សារជាមូលដ្ឋាននៃផល អនុផលព្រៃឈើដទៃទៀត ដែលពុំមានចែងក្នុងប្រការ ១ ខាងលើ នឹងត្រូវកំណត់តម្លៃជាក្រោយ ។

ប្រការ ៣ : តម្លៃទីផ្សារជាមូលដ្ឋាននៃឈើជ្រុង ឈើអារ ដែលបានកំណត់ក្នុងប្រការ១ ខាងលើ នឹងធ្វើការពិនិត្យកែសម្រួលឡើងវិញជារៀងរាល់ឆ្នាំនៅខែឧសភា ហើយករណីចាំបាច់អាចត្រូវកំណត់ឡើងវិញ តាមតម្រូវការជាក់ស្តែង។

ប្រការ ៤ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ៥ : អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធានអង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ០៦ ខែ[illegible] ឆ្នាំ ២០១០

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ជ័ន្ទ សារុន

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

កន្លែងទទួល:

- ខុទ្ទកាល័យព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- ដូចប្រការ ៥
- គ្រប់សាលាខេត្ត-រាជធានី
- ឯកសារ-កាលប្បវត្តិ